**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០៣៦....សហវ.[illegible]

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ រាជធានីភ្នំពេញ

## ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨.១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៥៨_អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសម្រេចលេខ ០០៤ សសរ.សហវ.ពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ០៦៧ សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញសំណើលេខ ១៦៩ សស.ហិរ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១០ របស់សាលារាជធានីភ្នំពេញ ស្តីពីការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅរាជធានីភ្នំពេញ ។

## សម្រេច

**ប្រការ ១.-** បង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | លោកស្រី ឆុច សារ៉ុម | អភិបាលរងរាជធានីភ្នំពេញ | ប្រធាន |
| ២. | លោក អោម ចន | អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធានប្រចាំការ |
| ៣. | លោក លី សារ៉េត | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | អនុប្រធាន |
| ៤. | លោក ឆាយ ឫទ្ធិសែន | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ | អនុប្រធាន |
| ៥. | លោក កើត ឆែ | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ៦. | លោក ខ៊ែត ចន្ថារី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ | សមាជិក |
| ៧. | លោក ផេង សុខាំ | ប្រធានមន្ទីរកសិកម្ម រាជធានីភ្នំពេញ | សមាជិក |
| ៨. | លោកស្រី មុំ សណ្តាប់ | ប្រធានមន្ទីរផែនការរាជធានីភ្នំពេញ | សមាជិក |
| ៩. | លោក ប៊ុន សេរី | នាយកទីចាត់ការហិរញ្ញវត្ថុសាលារាជធានីភ្នំពេញ | សមាជិក |
| ១០. | លោក ខឹម តុលា | ប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១១. | លោក ស៊ិន បូណ៌មី | នាយកទីចាត់ការរៀបចំក្រុង | សមាជិក |
| ១២. | លោក ប៊ុត សារ៉ែត | ប្រធានការិយាល័យហិរញ្ញកិច្ច | សមាជិក |
| ១៣. | លោក ហ៊ីល ធីរិត | អនុប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៤. | លោក គីម គន្ធារី | អនុប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៥. | លោក ហោ ម៉ាន់ហ៊ីម | អនុប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |

**ប្រការ ២.-** អនុគណៈកម្មការមានភារកិច្ច :

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងរាជធានីភ្នំពេញ
- លើកគម្រោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងរាជធានីភ្នំពេញ ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ពិនិត្យ និងសម្រេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនបានប្រើប្រាស់ ។

**ប្រការ ៣.-** អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ ។

**ប្រការ ៤.-** សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

**ប្រការ ៥.-** អនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការ និងត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៦.-** សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧.-** ឯកឧត្តម លោក-លោកស្រី ដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់**

**គាត វិបុល**

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- សាលារាជធានីភ្នំពេញ *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ដូចប្រការ៧ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ